# ឧបករណ៍ភ្លេងភ្លយ
# នៅតំបន់អារ៉ែង

# Phloy Musical Instrument **in Areng**




ថ្នាក់ឧបករណ៍ភ្លេង ភ្លយ
023 986 032
kmmb@cambodianlivingarts.org
www.kmmb.cambodianlivingarts.org

# មាតិកា Content

| | | |
|---|---|---|
| *អារម្ភកថា* | 4-8 | *Preface* |
| *ក្រុមការងារស្រាវជ្រាវ* | 9 | *Research Team* |
| *ឧបករណ៍ភ្លេងភ្លួយ* | 10 | *Musical Instrument Phloy* |
| **១. សេចក្តីផ្តើម** | 11-21 | **1. Introduction** |
| **២. អំពីឧបករណ៍ភ្លួយ** | 22-29 | **2. About the Phloy** |
| **២.១ រឿងនិទានអំពីប្រវត្តិឧបករណ៍ភ្លួយ** | 30-31 | **2.1. Tales of the Phloy** |
| **៣. របៀបធ្វើឧបករណ៍ភ្លួយ** | 32-41 | **3. How to Make the Phloy** |
| **៤. បទភ្លេងនិងចម្រៀង** | 42-53 | **4. Melodies and Lyrics** |
| **៥. សេចក្តីសន្និដ្ឋាន** | 54-55 | **5. Conclusion** |
| *ឯកសារពិគ្រោះ* | 56 | *References* |
| *អ្នកផ្តល់ព័ត៌មាន* | 57 | *Key Informants* |
| *ស្ថាប័នសហការ* | 58 | *Institutional Partners* |

# អារម្ភកថា Preface

ឧបករណ៍ក្លួយ[១] ជាឧបករណ៍ប្រភេទគ្រឿងផ្លុំម៉្យាងដែលធ្វើពីឫស្សីនិងឃ្លោក ដែលបច្ចុប្បន្នកំពុងប្រឈមនឹងការបាត់បង់ជាបណ្តើរៗ។ តំបន់អារ៉ែង ស្ថិតនៅក្នុងខេត្តកោះកុងមានជនជាតិដើមភាគតិចជង ដែលនៅតែបដិបត្តិជំនឿឡើងអ្នកតាជារៀងរាល់ឆ្នាំ ដោយមានឧបករណ៍ក្លួយសម្រាប់កំដរក្នុងកិច្ចពិធីនោះរៀងរាល់១ឆ្នាំម្តង។ ទោះជាយ៉ាងនេះក៏ដោយ ឧបករណ៍ក្លួយនៅតែប្រឈមមុខនឹងការបាត់បង់ ដោយសារពុំមានឱកាសក្នុងការសម្តែងជាសាធារណៈនៅក្នុងពិធីផ្សេងៗ ក៏ដូចជាមិនសូវមានអ្នកចាប់អារម្មណ៍រៀនឧបករណ៍នេះ។ ម៉្យាងវិញទៀត បទភ្លេងនៅក្នុងពិធីឡើងអ្នកតា តម្រូវឱ្យអ្នករៀន ចូលរួមក្នុងពិធីនេះជាប្រចាំ ទើបអាចរៀនបទសែនអ្នកតាស្រុកបាន។ ចំពោះការផលិតឧបករណ៍ក្លួយក្នុងពេលបច្ចុប្បន្នវិញ ក៏រឹងរឹតតែមានការលំបាកក្នុងការស្វែងរកវត្ថុធាតុដើមឱ្យបានសព្វមុខណាស់។

*[១]នៅក្នុងសៀវភៅដែលបានបោះពុម្ពដោយអ្នកនិពន្ធមុនៗ ខ្លះសរសេរថាក្លួយ ឯខ្លះសរសេរថាព្លួយ។ ដោយសារនាងខ្ញុំយល់ថា ស្តាប់សូរទៅ ពាក្យនេះ គួរសរសេរនឹងព្យញ្ជនៈ ក ដូចនេះ នៅក្នុងអត្ថបទទាំងមូល នាងខ្ញុំនឹងប្រើពាក្យឧបករណ៍ក្លួយ។*

The Phloy is a type of wind instrument made of bamboo tubes and dried birdhouse gourd that is gradually facing endangerment. The Areng region is in Koh Kong province and is inhabited by the indigenous Chong tribe, which is still practising the annual village spirit ritual of using the Phloy musical instrument to accompany the ceremony once a year. However, the Phloy still faces threat due to the lack of opportunities to perform in public at various events, as well as the lack of interest in learning about this remarkable instrument. On the other hand, the music for the Neak Ta spirit requires learners to regularly participate in the ceremony in order to learn the accurate melodies for Neak Ta songs. As for the production of the Phloy today, it is becoming harder and more difficult to find the raw materials necessary to make it.

នៅក្នុងការស្រាវជ្រាវនិងចងក្រងនេះ ក្រុមការងារបានសិក្សាពីប្រវត្តិខ្លះៗរបស់ឧបករណ៍ភ្លយ បទភ្លេងនិងចម្រៀងនៅក្នុងពិធីឡើងអ្នកតា របៀបធ្វើឧបករណ៍ភ្លយ និងបទចម្រៀងនៅក្នុងពិធីផ្សេងៗទៀតរបស់អ្នកស្រុកនៅតំបន់អារ៉ែង។ ជាការគួរឱ្យសោកស្តាយ អំឡុងពេលចុះស្រាវជ្រាវក្នុងឆ្នាំ២០២១នេះ លោកតាឌួង ញ៉ឹកដែលជាអ្នកចេះផ្លុំឧបករណ៍ភ្លយតែមួយគត់ មានវ័យកាន់តែជរាមិនអាចផ្លុំភ្លយបានទៀតឡើយ។ ពួកយើងបានត្រឹមស្តាប់សំឡេងភ្លយរបស់កូនសិស្សរបស់លោកតាប៉ុណ្ណោះ។ ដូចនេះហើយ ទើបការស្រាវជ្រាវនិងចងក្រងអំពីឧបករណ៍ភ្លយត្រូវតែធ្វើឡើងជាបន្ទាន់។ សាច់បទភ្លេងភ្លយមានប្រវែងខ្លីល្មម មានផ្នែកខ្លះនៃបទមានពីរសំឡេងឮដំណាលគ្នា ស្រដៀងទៅនឹងសំឡេងគែនដែរ តែខុសគ្នាត្រង់សំឡេងគែនឮសំឡេងគូ ឯភ្លយឮសំឡេងពីរឬបីខុសគ្នា។ ការចម្លងណោតភ្លេងបានសរសេរនៅក្នុងបញ្ជាររខា[២] បស្ចិមប្រទេស ដូច្នេះនៅក្នុងបទខ្លះមានវិភេទសញ្ញា[៣] ខាងដើមកូនសោររហូតដល់ទៅ៤។ ក្នុងការផលិតឧបករណ៍ភ្លេងភ្លយ លោកតាឌួង ញ៉ឹកមិនបានផៀបសំឡេងឱ្យត្រូវគ្នាទេ ដូច្នេះឧបករណ៍ភ្លយនីមួយៗមានសំឡេងមិនដូចគ្នាឡើយ។ លោកតាយល់ថា បទភ្លេងនឹងស្តាប់ទៅពីរោះបើភ្លយមានសំឡេងខុសៗគ្នា។

*[២]ជាបន្ទាត់៥ស្របគ្នា ប្រើសម្រាប់សរសេរណោតភ្លេង។ គេអាចសម្គាល់កម្ពស់សំឡេងនៃណោតភ្លេង ដោយសារបន្ទាត់ស្របទាំង៥នេះ។*
*[៣]ជាក្រុមនៃឌីយែស ឬមេប៉ុលដែលគេដាក់នៅខាងដើមនៃបទភ្លេងនីមួយៗ។ តន្ត្រីករត្រូវបញ្ចុះ ឬតម្លើងសំឡេងណោតភ្លេងទៅតាមវិភេទសញ្ញាទាំងនោះ។*

In this research and compilation, our team studied the history of the Phloy, its melodies and songs used for the Neak Ta spirit ritual, as well as how to make the Phloy and some songs for other ceremonies of Areng inhabitants. Unfortunately, during the research trip in 2021, Grandpa Duong Nhek was the only one who knew how to play the instrument but he was too old and no longer able to perform. With no choice, we could only hear his students play the Phloy. Subsequently, research and documenting of the Phloy must be conducted urgently.

The melody of Phloy music is short enough; some parts of the song have two sounds heard simultaneously, like the sound of Ken music. However, the Ken produces a related pair of notes across octaves, whereas the Phloy produces two or three sounds separately and distinctly. The musical transcription is written in Western music notation, thus in some songs, there are up to four flats key signature changes [1] .

When making the Phloy, Grandpa Duong Nhek does not tune the instrument, so each one sounds unique. Grandpa thought the music would sound beautiful if each instrument had incongruous sound.

[1] *The Khmer scale is different than the Western scale. Khmer does not use key signatures or accidentals in music. Don't think about key signature with Khmer traditional instruments.*

ថ្នាក់បង្រៀនភ្លយដែលបង្រៀនដោយលោកតា ឌួង ញ៉ឹក ចាប់ផ្តើមបើកបង្រៀនតាំងពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន ក្នុងគោលបំណងបណ្តុះបណ្តាលសិស្ស ឱ្យចេះផលិតឧបករណ៍ភ្លយ ចេះច្រៀងនិងផ្លុំឧបករណ៍ភ្លយ។ សិស្សរបស់លោកតា នឹងបន្តផ្ទេរចំណេះដឹងក៏ដូចជាផ្សព្វផ្សាយទៅកាន់តំបន់ផ្សេងៗទៀតអំពីឧបករណ៍ភ្លយឱ្យកាន់តែទូលំទូលាយ។ យើងខ្ញុំសង្ឃឹមថា មរតកសិល្បៈនិងវប្បធម៌របស់តំបន់អារ៉ែងនឹងស្ថិតស្ថេរគង់វង្ស សម្រាប់មនុស្សច្រើនជំនាន់ក្រោយទៀត ពីព្រោះសិល្បៈនិងវប្បធម៌ជាអត្តសញ្ញាណរបស់ប្រទេសមួយ ឬជនជាតិមួយ ដោយពុំអាចនឹងមានអ្វីមកជំនួសបានឡើយ។

Phloy classes taught by Grandpa Duong Nhek started in 2018 and continue to present day, aiming to train students in playing Phloy music and songs, as well as learning how to make the instrument. Grandpa's students will continue to educate others and broadly promote Phloy music to other regions. We all hope that this artistic heritage of the Areng region will be safeguarded for generations to come, because arts and culture are the irreplaceable identities of a nation or an ethnic group.



# ក្រុមការងារស្រាវជ្រាវ Research Team

**ឥន្ទ សម៉ាណាក់**
អ្នកសម្របសម្រួល

**En Sormanak**
Facilitator

**វ៉ា បុប្ផារី**
អ្នកស្រាវជ្រាវ

**Va Bophary**
Researcher

**ថន សីម៉ា**
អ្នកសម្របសម្រួល

**Thorn Seyma**
Facilitator

**ថន ដីកា**
អ្នកថតរូប

**Thon Dika**
Photographer

# ឧបករណ៍ភ្លេងភ្លយ
# Musical Instrument Phloy



# ១. សេចក្ដីផ្ដើម

# 1. Introduction

ឧបករណ៍តន្ត្រីបុរាណនៅក្នុងប្រទេសកម្ពុជានីមួយៗ មានតួនាទីខុសៗគ្នាទៅតាមកិច្ចពិធី ឬវង់ភ្លេងដែលប្រគំ។ ឧបករណ៍ភ្លេងភ្លយ[៤] ជាប្រភេទឧបករណ៍គ្រឿងផ្លុំរបស់ជនជាតិដើមភាគតិច ដែលយើងឃើញមាននៅតាមបណ្ដាខេត្តនានាដូចជា ខេត្តពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ និងកោះកុងជាដើម។ ឧបករណ៍ភ្លយគេប្រើនៅក្នុងពិធីជាទំនៀមទម្លាប់របស់អ្នកស្រុកដូចជា ពិធីឡើងអ្នកតា ពិធីសែនព្រេន ពិធីបញ្ជាន់អារក្ស ឡើងព្រៃដំរី និងពិធីចាប់ជើងដំរី[៥] ជាដើម។ ពិធីឡើងអ្នកតាគេធ្វើឡើងរៀងរាល់១ឆ្នាំម្ដងនៅក្នុងខែមាឃ[៦] ដោយមានឧបករណ៍ភ្លយនិងស្គរដៃកំដរ។ ចំណែកនៅក្នុងពិធីជាមង្គលមានដូចជាពិធីមង្គលការ ឬមង្គលការផ្ដាច់[៧] គេមិនប្រើឧបករណ៍ភ្លយទេ។

*[៤]នៅក្នុងអត្ថបទស្រាវជ្រាវមុនៗ យើងឃើញមានពាក្យភ្លយនិងព្លយ។*

*[៥]ជាពិធីគេធ្វើឡើងក្រោយពេលចាប់ដំរីបាន គេត្រូវធ្វើឱ្យដំរីនោះស្លូតព្រមស្ដាប់តាមបញ្ជាទ្រមាក់ ដោយប្រើឧបករណ៍ភ្លយផ្លុំបន្ទន់ចិត្តដំរី។*

*[៦]នៅក្នុងខែសុរិយគតិ ប្រហែលក្នុងខែកុម្ភៈឬខែមីនា។*

*[៧]មង្គលការផ្ដាច់មានន័យថា ម្ដាយឪពុកខាងកូនស្រីបង្គាប់បណ្ណាការមានតម្លៃថ្លៃទៅខាងកូនប្រុស។ បន្ទាប់ពីរៀបការរួច កូនស្រីមិនមានសិទ្ធិរាប់រកម្ដាយឪពុកនិងក្រុមគ្រួសាររបស់ខ្លួនឯងទៀតឡើយ។*

Each traditional musical instrument in Cambodia has a different role depending on the relevant ritual or ensemble accompaniment. The Phloy is a type of wind instrument used by indigenous people in many provinces, such as Pursat, Kampong Chhnang, Kampong Speu and Koh Kong. The Phloy is used in traditional ceremonies such as the Neak Ta spirit ceremony, offerings, possessions or trance rituals, elephant trapping and the leg-tied elephant rite[2]. The Neak Ta ceremony is held once a year in Meak[3] (the third month of Khmer lunar calendar), accompanied by the Phloy and hand drum. However, for a wedding ceremony or Mongkul-Kar-Pdach[4], the Phloy is not used.

*[2]The leg-tied elephant is a ritual performed after the elephant is captured, to make the elephant obey the order of the mahout, by using the Phloy to soften the elephant's heart and making it behave docilely.*

*[3]In Solar month, it is around February and March.*

*[4]Mongkul-Kar-Pdach is a wedding ceremony in which the bride's parents demand an expensive dowry from the groom's parents. After marriage, the daughter is disowned by her family.*

លោកតា ឃឹម យន់ ជាអ្នកច្រៀងនិងលេងស្គរ សព្វថ្ងៃរស់នៅភូមិកោះ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង បានរៀបរាប់ថា «តាំងតែពីដើមរៀងមក នៅពេលអ្នកស្រុកមានជំងឺ គេតែងរៀបពិធីសែនអ្នកតា ដោយមានឧបករណ៍ភ្លយលេងកំដរហើយពួកគេក៏បានសុខសប្បាយកន្លងមក»។ ប៉ុន្តែបច្ចុប្បន្ននេះ ដោយសារការរីកចំរើននៃវិទ្យាសាស្ត្រសុខាភិបាល ធ្វើឱ្យប្រជាជនខ្លះ បានបោះបង់ការសែនព្រេនអ្នកតាដែលធ្លាប់បដិបត្តិកន្លងមក។ លោកតាមិនចង់ឱ្យបាត់បង់ទំនៀមទម្លាប់តាំងពីបុរាណមកទេ ជាពិសេសឧបករណ៍ភ្លេងភ្លយ ដែលសព្វថ្ងៃបានក្លាយជាឧបករណ៍ភ្លេងដ៏កម្រដែលត្រូវតែថែរក្សា និងផ្សព្វផ្សាយបន្តឱ្យប្រជាជននៅក្នុងសហគមន៍របស់គាត់បានយល់ដឹងកាន់តែច្បាស់ពីសារសំខាន់របស់មរតកមួយនេះ។ នៅតំបន់អារ៉ែងបច្ចុប្បន្ន ក្រៅពីឧបករណ៍ភ្លេងភ្លយ ពុំមានវង់ភ្លេងផ្សេងទៀតដែលបម្រើឱ្យពិធីបុណ្យជាប្រពៃណីឬសាសនាឡើយ។ នៅពេលប្រារព្ធពិធីផ្សេងៗពួកគាត់ត្រូវជួលក្រុមភ្លេងមកពីខេត្តកោះកុងឬតាកែវដូចជាវង់ភ្លេងការ ឬវង់ភ្លេងពិណពាទ្យជាដើម។ លោក ឡូ ទិត ជាប្រជាជននៅភូមិចំណារ ឃុំប្រឡាយ ស្រុកថ្មបាំង ខេត្តកោះកុង ជាអ្នកលេងស្គរក្រុក និងជាអ្នកធ្វើស្គរក្រុកបានរៀបរាប់ថា «កាលពីមុនធ្លាប់មានវង់ភ្លេងការបុរាណសម្រាប់កំដរពិធីមង្គលការដែរ ហើយវង់ភ្លេងនោះគឺមានតែស្គរក្រុកមួយនិងអ្នកច្រៀងម្នាក់ប៉ុណ្ណោះ»។ ស្គរក្រុកមានរូបរាងដូចស្គរឃឹកេ ដែលលេងកំដរល្ខោនឃីកេ។ ស្គរក្រុកធ្វើអំពីឈើត្រសេក ពាសដោយស្បែកគោឬស្បែកឈ្លូស។ ក្រៅពីពិធីមង្គលការ ស្គរក្រុកកំដរនៅក្នុងពិធីបុណ្យបែបសាសនា។ នៅក្នុងពិធីបុណ្យខ្លះ គេប្រើស្គរក្រុករហូតដល់១០ឯណោះ។ ស្គរក្រុកដែលគេប្រើញឹកញាប់ជាងគេ គឺក្នុងកិច្ចក្រុងពាលី មុនពេលព្រះសង្ឃចាប់ផ្តើមកិច្ចនមស្ការព្រះរតនត្រ័យ។ ក្នុងកិច្ចក្រុងពាលីគេច្រៀងចម្រៀង១បទអមដោយស្គរក្រុក។ បច្ចុប្បន្ននេះស្គរក្រុកពុំសូវមានវត្តមាននៅក្នុងពិធីបុណ្យឬពិធីមង្គលការទៀតឡើយ ដោយជំនួសមកវិញដោយការចាក់ភ្លេងតាមកាសែត ឬស៊ីឌីជាដើម។

“Customarily, when the inhabitant was unwell and ill, the Neak Ta spirit ritual would be held with accompanying Phloy music, then contentment is returned to people,” described Grandpa Yim Yun, a singer and drummer living in Koh village, Thmor Daun Pov commune, Thmor Bang district, Koh Kong province. Nowadays with the advancement of medical sciences, many people no longer practise such supernatural beliefs. Grandpa does not want the ancient tradition to disappear, particularly the Phloy, which today has become a rare instrument that must be safeguarded and promoted to the people within communities to better understand the significance of our heritage. Presently in the Areng region, apart from the Phloy, there is no other music ensemble that serves traditional or religious rituals. When there is a ceremony, a wedding ensemble or Pin Peat music is hired from Koh Kong or Takeo province.

“In the past, there was an ensemble for wedding music and that ensemble only consisted of one Skor Kruk drum and a singer,” recounted Mr Lo Tith, a resident of Chamnar village, Prolay commune, Thmor Bang district, Koh Kong province, who is a Skor Kruk drummer and the instrument maker. The Skor Kruk drum looks like the Skor Yike drum of the Lakhaon Yike drama. The Skor Kruk drum is made of a kind of wood (Peltophorum ferrugineum) covered with cowhide. In addition to marriage, the Skor Kruk drum also accompanies religious

rites and in some grandeur ceremonials; up to 10 drums are used. The most common Skor Kruk drum is used during the spirit offerings, like the Krong Peali ritual, just before the Buddhist monks begin reciting the Dhamma. During the Krong Peali ritual, there is a song performed with the Skor Kruk drum. Nowadays, such a drum is no longer present at the ritual or wedding ceremony; instead it is played on tapes or CDs.

រូបទី១៖
**ស្គរក្រុក**

Photo 1:
**Skor Kruk drum**



តំបន់អារ៉ែង គ្របដណ្តប់លើឃុំចំនួនបីដូចជា ឃុំជំនាប់ ឃុំប្រឡាយ និងឃុំថ្មដូនពៅ។ លោកមេឃុំថ្មដូនពៅឈ្មោះ សៀង ថន បានឱ្យដឹងថា ប្រជាជនដែលរស់នៅក្នុងឃុំថ្មដូនពៅមានប្រមាណ ២០០គ្រួសារ នៅក្នុងនោះមានជនជាតិដើមភាគតិចជង ចំនួន៦១គ្រួសារ។ ប្រជាជនភាគច្រើន ពួកគេប្រកបរបរដាំស្រូវ ដាំបន្លែ ដំណាំវិលជុំផ្សេងៗ អនុផលព្រៃឈើ និងរកត្រី។ ពួកគេមានត្រណមតឹងរឹងណាស់នៅពេលចូលព្រៃ មិនតែប៉ុណ្ណោះក៏មានចម្រៀងសម្រាប់អង្វរករអ្នកតាដែលថែរក្សាព្រៃដើម្បីសុំសេចក្តីសុខ។ ពាក្យច្រៀងមានដូចជា[៨] ៖

*អេ អើយខ្ញុំមកពីនាយធ្លាក់អាយ ធ្លាក់អាយ ណា លោកអើយ ឱ្យខ្ញុំទីពឹងលោកណា អេអើយ ឱ្យទីពឹងលោកណា ឃុំគ្រងរក្សាខ្ញុំផង ក្រែងជើងខ្ញុំភ្លាត់ ក្រែងមាត់ខុសឆ្គង គ្រងរក្សាខ្ញុំផង ខ្លួនខ្ញុំក្មេងនៅ។*

ពាក្យច្រៀងនេះ ខុសៗគ្នាពីអ្នកច្រៀងម្នាក់ទៅម្នាក់ទៀត។ ទំនុកទាំងនេះសុទ្ធតែជាទំនុកមិនបានព្រៀងទុក ពោលគឺដល់ពេលច្រៀង រកនឹកពាក្យច្រៀងតែម្តង។ ដូច្នេះពាក្យច្រៀងរបស់គាត់មិនដូចគ្នាឡើយ រាល់ពេលច្រៀងម្តងៗ។

*[៨]ពាក្យច្រៀងនេះ បានមកពីលោក ឡូ ទិត នៅភូមិចំណារ ឃុំប្រឡាយ ស្រុកថ្មបាំង ខេត្តកោះកុង។*

The Areng region is covered three communes: Chumnab, Pralay and Thmor Daun Pov. Thmor Daun Pov commune chief Mr Sieng Thorn stated that about 200 families are living in the commune, including 61 indigenous families. Most of the population is engaged in growing rice, farming, producing non-timber forest products and fishing. For people who fish and produce non-timber forest products, they practise stricter proscriptive norms while entering the forest, such as songs for begging the forest spirits to offer their blessing. The song wording[5] is as follow:

***"Ooh Spirit, I come from far away, I have no one, but I count on you to protect me, if my legs are wobbly or my mouth is speaking badly, as I am still young."***

The lyrics vary from singer to singer. These hymns are unprepared, so when it comes time to sing, the singer improvises instantaneously, so the lyrics are never the same.

*[5]This lyric comes from Mr Lou Tith, a resident of Chamnar village, Prolay commune, Thmor Bang district, Koh Kong province.*

សព្វថ្ងៃនេះមនុស្សពេញវ័យមួយចំនួន បានចេញទៅធ្វើការនៅទីក្រុងឬក្រៅប្រទេស បន្សល់ទុក
នៅតែមនុស្សវ័យចំណាស់នៅចាំផ្ទះ។ បច្ចុប្បន្នយើងពិបាកនឹងសម្គាល់ថាតើជនជាតិដើមភាគតិចជងនៅតំបន់
អារ៉ែងមានលក្ខណៈខុសពីជនជាតិខ្មែរដូចម្តេច ដោយសារតែពួកគេនិយាយភាសាខ្មែរ ស្លៀកសម្លៀកបំពាក់តាមបែបខ្មែរ និង
កាន់សាសនាព្រះពុទ្ធដូចប្រជាជនខ្មែរទូទៅ តែពួកគេក៏នៅតែបដិបត្តិជំនឿបែបព្រលឹងនិយមដែរ។ ក្មេងៗនិងយុវជនមិនចាំភាសា
ជងរបស់ពួកគេឡើយ ពីព្រោះពួកគេបានចូលរៀននិងនិយាយភាសាខ្មែរទៅហើយ។ បច្ចុប្បន្នមានតែមនុស្សវ័យចំណាស់ ទើបនៅចាំ
និងនិយាយភាសាជងបាន។ មានរឿងដំណាលតៗគ្នារបស់អ្នកស្រុក អំពីដើមកំណើតជនជាតិដើមភាគតិចជងរបស់តំបន់អារ៉ែង
មកថា៖

Currently, some adults have gone to work in the city or across the border, leaving elderly people at home. It is difficult to tell how the Chong ethnic tribe in the Areng region is different from Khmer people because they speak the Khmer language, they opt to wear Khmer clothing and practise Buddhism like the typical Cambodian population, despite still believing in animism. Children and young people do not remember the Chong dialect because they learned the Khmer language while going to school. Mainly older people can remember and know how to speak the Chong dialect. This is a tale about the origins of the Chong tribe in the Areng region:

*នៅក្នុងសម័យឧដុង្គ មានព្រះរាជាមួយអង្គ បានចេញព្រះរាជបញ្ជាឱ្យព្រាហ្មណ៍៨នាក់ ចេញទៅរកសត្វដំរីភ្លុកសមកថ្វាយ។ ព្រាហ្មណ៍ទាំង៨ ក៏ធ្វើដំណើរមកដល់ភូមិកោះ (ពីដើមគេហៅថាភូមិជាំស្លា) ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុងសព្វថ្ងៃ ដើម្បីរុករកដំរីភ្លុកស តែទោះជាខំរកយ៉ាងណា ក៏រកមិនឃើញ។*

*ព្រាហ្មណ៍ទាំង៨បានពិភាក្សាគ្នាថា បើសិនជាយើងត្រឡប់ទៅវិញដោយគ្មានដំរីភ្លុកសទៅជាមួយ ច្បាស់ជាត្រូវស្តេចប្រហារជីវិតជាមិនខាន ដូច្នេះត្រូវរកឧបាយដើម្បីកុហកស្តេច។ គិតគ្នារួចព្រាហ្មណ៍ទាំង៨ ក៏ត្រឡប់ទៅក្រាបទូលស្តេចថាបានរកឃើញដំរីហើយ តែត្រូវការចំណាយពេលយូរទៀតដើម្បីតាមចាប់ដំរីនោះ ហើយក៏ត្រូវការស្បៀងបន្ថែមទៀតដែរ។ នៅពេលបានស្បៀងបន្ថែមល្មមគ្រប់គ្រាន់ ព្រាហ្មណ៍ទាំង៨ ក៏នាំយកក្រុមគ្រួសាររៀងៗខ្លួន មកតាំងលំនៅត្រង់ម្តុំភូមិកោះ តំបន់អារ៉ែងសព្វថ្ងៃនេះ លែងត្រឡប់ទៅផ្ទះសម្បែងខ្លួនវិញរហូត[៩] ។*

យោងទៅតាមរឿងដែលដំណាលមកនេះ អ្នកនៅតំបន់អារ៉ែងសព្វថ្ងៃជឿថា ដូនតារបស់ពួកគាត់ជាជនជាតិខ្មែរ ដែលធ្លាប់រស់នៅក្នុងរាជធានី រួចភៀសខ្លួនមករស់នៅតំបន់ព្រៃភ្នំ ជ្រលងជងអូរក្នុងសម័យឧដុង្គ ដើម្បីឱ្យរួចផុតពីការប្រហារជីវិតរបស់ស្តេច។ ដូច្នេះពួកគាត់យល់ថា ពាក្យជង គឺមកពីពាក្យជ្រលង ដែលមានន័យថា អ្នកដែលរស់នៅតាមជ្រលងភ្នំនេះឯង។

*[៩]រឿងនេះដំណាលដោយលោកមេឃុំ សៀង ថន ជាមេឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង។*

*"During the Udong period, a king ordered eight Brahmins to go hunting for the white ivory elephant. The eight Brahmins travelled and arrived at Koh village (formerly known as Choam Sla village) that is in the modern-day Thmor Daun Pov commune, Thmor Bang district, Koh Kong province. They were in search of the white ivory elephant, but no matter how hard they tried, they could not find it. The eight Brahmins knew if they returned without the white ivory elephant, they would surely be executed by the king, therefore they had to find a trick to play on the king. After coming to an agreement, the eight Brahmins returned to tell the king that they had found a trace of the elephant, but it would take more time and food to catch. Once they obtained enough food, the eight Brahmins brought their family members to settle at the Koh village of today's Areng region, never to return back to their homes[6]."*

According to this folktale, people in the Areng region today believe their ancestors were Khmer people who once lived in the Udong capital and fled to the mountains and valleys to escape from the execution by the king. Therefore, they thought the term "Chong" was derived from the valley, which means "those who live in this valley".

[6] *This tale is narrated by Mr Sieng Thorn, Thmor Daun Pov Chief of Commune in Thmor Bang district, Koh Kong.*



# ២. អំពីឧបករណ៍ភ្លួយ About the Phloy 2.

ឧបករណ៍ភ្លួយមានលក្ខណៈខុសៗគ្នាបន្តិចបន្តួចទៅតាមតំបន់នីមួយៗ។ ជាពិសេសប្រអប់សំនៀងខ្លះធ្វើពីផ្លែឃ្លោកទុំ ខ្លះធ្វើពីត្រឡោកដូងជាដើម អាស្រ័យទៅលើការរចនារបស់ជាងផលិតឧបករណ៍ តាមតំបន់ខុសៗគ្នា ឬទៅតាមធនធានដែលមាន។ ទោះបីជារូបរាងភ្លួយ និងបទចម្រៀងមានលក្ខណៈមិនដូចគ្នា តែគោលបំណងក្នុងការលេងឧបករណ៍ភ្លួយក្នុងន័យតែមួយគឺ ការបន់ស្រន់ អង្វរករដល់អ្នកតាដែលថែរក្សាស្រុកភូមិ។

The Phloy varies slightly from region to region. Some resonator boxes are made of dried birdhouse gourd and some are made of dried coconut shells, depending on the design of the instrument maker in different areas and the available resources. Although the appearance of the Phloy and the characteristics of the song are not the same, the purpose of playing the Phloy remains relatively the same, that is, to pray to the guardian spirits who protect and bless the village.



រូបទី២៖
ឧបករណ៍ភ្លេងភ្លយ

Photo 2:
**Musical Instrument Phloy**

ក្រៅពីតំបន់អារ៉ែង ក្នុងខេត្តកោះកុង នៅខេត្តកំពង់ស្ពឺសព្វថ្ងៃ ដូចជាភូមិជំនាប់ ឃុំសង្កែសាទប និង ភូមិកោដូនតី ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺក៏មានប្រើឧបករណ៍ភ្លេយនៅក្នុងពិធីបុណ្យប្រចាំឆ្នាំរបស់គេដែរ។ ឧបករណ៍ភ្លេយគេលេងសម្រាប់អន្ទងក្នុងពិធីឡើងសំណំ[១០] និងពិធីលាបំណន់របស់ជនជាតិដើមភាគតិចសួយ នៅស្រុកឱរ៉ាល់។ នៅក្នុងពិធីរបស់ជនជាតិដើមភាគតិចសួយ ក្រៅពីឧបករណ៍ភ្លេយ នៅមានកង (រូបរាងស្រដៀងនឹងឈិងរបស់ខ្មែរ) និងស្គរ។ របាំភ្លេយរបស់ជនជាតិដើមភាគតិចសួយ[១១] ដែលរស់នៅក្បែរជើងភ្នំឱរ៉ាល់ ត្រូវបានក្រុមអ្នកស្រាវជ្រាវនៅនាយកដ្ឋានសិល្បៈនិងវប្បធម៌ខេត្តកំពង់ស្ពឺ រួមជាមួយអ្នកតម្លើងរបាំគឺលោកគ្រូ អន ជាហេង បានយកមកសម្រួលទាំងបទភ្លេង ក្បាច់រាំ និងសម្លៀកបំពាក់នៅក្នុងឆ្នាំ១៩៩៦[១២]។ ចាប់ពីពេលនោះមក របាំភ្លេយសួយត្រូវបានគេស្គាល់និងយកមកសម្តែងនៅតាមបណ្តាខេត្តនិងរាជធានី ពេលមានកម្មវិធីសម្តែងសិល្បៈឬមហោស្រពនានា។

---

*[១០]ពិធីឡើងសំណំ ជាពិធីអបអរមួយដែលធ្វើឡើង១ឆ្នាំម្តងក្រោយការច្រូតកាត់រួច ក្នុងខែពិសាខឬជេស្ឋ (ខែមិថុនាឬកក្កដា) ពេលដែលអ្នកភូមិទាំងអស់ទំនេរពីការងារស្រែចម្ការ។*

*[១១]ជនជាតិដើមភាគតិចសួយនៅខេត្តកំពង់ស្ពឺមានបែងចែកជា សួយកន្តែរ៉ែ សួយចន្លុះ និងសួយម្លូ (សម្ភាសជាមួយលោកស៊ុន មានជ័យ ប្រធានមន្ទីរវប្បធម៌ខេត្តកំពង់ស្ពឺ)*

*[១២]បញ្ជីសារពើភ័ណ្ឌបេតិកភណ្ឌវប្បធម៌អរូបី, ២០០៤ ទំព័រ៥៨*

Apart from the Areng region of Koh Kong, in present day, the Phloy is also used at the annual ceremonies in some areas of Kampong Speu province such as Chhumnab village of Sangke Satorb and Dauntey village of Trapeang Cho commune in Aoral district. The Phloy is performed during the ritual Leung-Somnum[7] and Lea-Bamnon of the Suoy[8] indigenous people in Aoral district, Kampong Speu province. In the tribal Suoy ceremony, apart from the Phloy, there is a Gong (like a Khmer Cymbal) and a drum. Robam Phloy Suoy (Phloy Suoy dance), an indigenous dance of Suoy inhabitants around the foot of Aoral mountain, was adapted by the research team of Kampong Speu Department of Culture and Fine Arts with folk dance master Mr An Chhea Heng, who rearranged music, choreographed the dance and designed costumes in 1996[9]. Since then, Robam Phloy Suoy has been known and performed across the country at various events and festivals.

[7] *Leung-Somnum is an annual celebration of crop-harvesting (around June and July) when the villagers take a break from farming the field.*

[8] *Suoy indigenous tribes in Kampong Speu are categorised into Suoy-Kantere, Suoy-Chanlos & Suoy-Mou (interviewed with Mr Sun Meanchey, Director of Department of Culture and Fine Arts, Kampong Speu).*

[9] *Inventory of Intangible Cultural Heritage of Cambodia (2004) MoCFA & UNESCO.*

ចំណែកជនជាតិដើមភាគតិចជង និងព័រនៅខេត្តពោធិ៍សាត់ក៏ប្រើឧបករណ៍ភ្លយសម្រាប់ក្នុងពិធីសែនព្រេន បន់ស្រន់ផ្សេងៗ ពិធីឡើងអ្នកតានិងឡើងអារក្ស។ មិនត្រឹមតែប៉ុណ្ណោះ ឧបករណ៍ភ្លយ ត្រូវគេយកមកផ្លុំកំដរនៅក្នុងពិធីមង្គលការថែមទៀតផង[១៣] ខុសប្លែកពីតំបន់អារ៉ែងដែលគេប្រើតែនៅក្នុងពិធីឡើងអ្នកតាតែប៉ុណ្ណោះ។ ជនជាតិដើមភាគតិចជង និងព័រនៅខេត្តពោធិ៍សាត់ មានជំនឿថាឧបករណ៍ភ្លយនេះគឺអ្នកតាជាអ្នករកឃើញនូវគំនិតច្នៃប្រឌិតឧបករណ៍ភ្លយនេះឡើង ដូច្នេះគេមិនដែលយកឧបករណ៍ភ្លយទុកជាកម្មសិទ្ធិនៅផ្ទះរបស់នរណាម្នាក់ឡើយ គេតែងតែទុកឧបករណ៍ភ្លយ នៅនឹងខ្ទមអ្នកតាណាមួយដែលមានសុវត្ថិភាពដើម្បីយកមកប្រើពេលក្រោយទៀត។ ក្រៅពីពិធីដែលរៀបរាប់ខាងលើ ឧបករណ៍ភ្លយក៏មាននាទីពិសេសក្នុងការប្រគំកំដរក្នុងពិធីបែរបន់មុនពេលចេញទៅបេះក្រវាញ និងពេលបេះក្រវាញរបស់អ្នកស្រុកនៅតំបន់ភ្នំក្រវាញនិងវាលវែង។

នៅតំបន់អារ៉ែង ខេត្តកោះកុង ឧបករណ៍ភ្លយ ជាឧបករណ៍ភ្លេងកម្រមួយ ដែលពុំសូវមាននរណាស្គាល់និងឮសំឡេងរបស់ឧបករណ៍នេះដោយសារតែគេលេងតែក្នុងពិធីឡើងអ្នកតាតែប៉ុណ្ណោះ។ បច្ចុប្បន្ននេះមានតែលោកតា ឌួង ញ៉ឹក អាយុ៨៧ឆ្នាំ រស់នៅក្នុងភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុងតែម្នាក់គត់ដែលនៅចេះលេងឧបករណ៍ភ្លយ។ លោកតាបានរៀនឧបករណ៍ភ្លយពីលោកតារបស់គាត់ឈ្មោះសែម តាំងពីគាត់មានអាយុ២០ឆ្នាំ។ លោកតា ឌួង ញ៉ឹក មានការបារម្ភ ដោយសារមិនមានអ្នកចង់រៀនឧបករណ៍ភ្លយបន្តពីគាត់។ សូម្បីតែកូនស្រីបង្កើតទាំង៣នាក់របស់គាត់ក៏មិនចង់លេងឧបករណ៍ភ្លយដូចគាត់ដែរ។

---

[១៣] *កម្ពុជសុរិយា, លេខ៤ ឆ្នាំ២០០១ ទំព័រ៨៨-៩៣*

For indigenous tribes of Chong and Por in Pursat province, the use of the Phloy for various rituals is also in reverence to sacred beings, guardians and cave spirits. Not only that, but the Phloy is also used to accompany wedding ceremonies[10], unlike in the Areng region where it is only used for the Neak Ta spirit ritual. The indigenous Chong and Por of Pursat believe the Phloy was invented by the Neak Ta spirit, therefore the Phloy is never owned or kept at an individual household, it is always being kept at a hut of the Neak Ta spirit and safely retrievable for the next use. In addition to the ceremonies described above, the Phloy also has a special role in accompanying the ceremony before going out to pick cardamom and during the cardamom-picking time for the locals in the Veal Veng district and the Cardamom Mountains.

In the Areng region of Koh Kong, the Phloy is a rare musical instrument that is usually unknown because it is solely played during the annual Neak Ta spirit ritual. Presently, only Grandpa Duong Nhek, age 87, from Prek Svay village, Thmor Daun Pov commune, Thmor Bang, Koh Kong province, still knows how to play the Phloy. He learned to play the Phloy when he was 20 years old from his grandfather named Sem. Grandpa Duong Nhek expressed that he is worried because no one is interested in learning the art from him. Even his three biological daughters do not want to learn to play the Phloy like him.

[10] *Kambuja Suriya, Issue 4 (2001), page 88-93.*

ជាភ័ព្វសំណាងល្អ ដោយសារការខិតខំប្រឹងប្រែងនិងជ្រោមជ្រែងពីរថយន្តតន្ត្រីទិព្វខ្មែរនៃអង្គការ
សិល្បៈខ្មែរអមតៈ មូលនិធិពីឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា (មូលនិធិឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកសម្រាប់
ការអភិរក្សវប្បធម៌) និងការសម្របសម្រួលពីសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង ថ្នាក់បង្រៀនភ្លុយបានបើកបង្រៀនសិស្ស
ក្នុងឆ្នាំ២០១៨។ លោកតាបានផ្ទេរចំណេះដឹងរបស់គាត់ទាំងការលេងឧបករណ៍ ច្រៀងចម្រៀង និងរបៀបធ្វើឧបករណ៍ភ្លុយ ឱ្យទៅ
សិស្សរបស់គាត់បានចំនួន៣នាក់ហើយក្នុងចំណោមនោះមានស្រី២នាក់។ សិស្សទាំង៣នាក់ត្រូវធ្វើដំណើរតាមផ្លូវដែលមានសភាព
លំបាក និងឆ្ងាយពីផ្ទះរបស់ពួកគេ ដើម្បីមករៀនភ្លុយនៅផ្ទះលោកតា ឌួង ញ៉ឹក។

Fortunately, thanks to the hard work and strong support of the Khmer Magic Music Bus of Cambodian Living Arts, a grant from the US Ambassador to Cambodia (US Ambassador Fund for Cultural Preservation) and great facilitation from the Steung Areng Community-Based Ecotourism, a Phloy class was opened to teach the musical instrument in 2018.

Grandpa cheerfully transferred all his knowledge in playing the Phloy, singing and instrument-making to his three talented students, two of whom were girls. Those three learners had to travel on a difficult dirt road and far away from their homes to learn the Phloy at Grandpa Duong Nhek's house.





រូបទី៣និងទី៤៖
**ថ្នាក់បង្រៀនភ្លុយ**

Photo 3&4:
**Phloy Class**

# ២.១ រឿងព្រេងនិទានអំពីប្រវត្តិឧបករណ៍ភ្លយ

# 2.1 Tales of the Phloy

លោកតាឃឹម យន់ បានដំណាលអំពីប្រវត្តិរបស់ឧបករណ៍ភ្លយថា កាលពីយូរលង់ណាស់មក ហើយ *មានស្តេចមួយអង្គ (មិនចាំព្រះនាម) បានប្រើព្រានឱ្យទៅបរបាញ់សត្វនៅក្នុងព្រៃ។ ពេលទៅដល់ព្រៃ ព្រានប្រមាញ់បានឃើញទិដ្ឋភាពមួយគួរឱ្យជក់ចិត្តគឺសត្វទន្សោង១គូកំពុងប្រជល់គ្នា រីឯសត្វកន្លង់មួយហ្វូងកំពុងរោមផ្កា ស្រែកច្រៀងយ៉ាងគ្រលួចពីលើសត្វទន្សោងទាំងពីរនោះ។ ក្នុងពេលនោះដែរមានសត្វខ្លាមួយពួនក្នុងគុម្ពោតព្រៃដែលប៉ុនប៉ងប្រុងស៊ីសត្វទន្សោង ក៏បែរជាគោះកន្ទុយជាចង្វាក់ភ្លេង រីឯព្រានប្រមាញ់ក៏លើកដៃរកបាញ់សត្វទន្សោងមិនកើត ដោយសារតែទិដ្ឋភាពនោះហាក់ដូចជាផ្ទាំងទស្សនីយភាពដ៏ល្អមួយនៅកណ្តាលព្រៃ។*

*ព្រានព្រៃ ក៏ត្រឡប់ទៅទូលស្តេចតាមដំណើររឿង ស្តេចទ្រង់ជ្រាបហើយក៏បញ្ជាឱ្យព្រានធ្វើត្រាប់តាមទិដ្ឋភាពដែលព្រានព្រៃបានឃើញ។ ព្រានព្រៃបានរៀបចំវង់ភ្លេងមួយវង់ ត្រាប់តាមហេតុការណ៍ដែលគាត់បានឃើញដូចជា ឧបករណ៍ភ្លយជាតំណាងសត្វកន្លង់រោមផ្កា (ឮសូររ៉ៃៗ) រីឯទន្សោងពីរក្បាល គេធ្វើត្រាប់ដោយយកស្នែងទន្សោងមកពាក់លើក្បាលមនុស្សពីរនាក់រាំតាមបទភ្លេង ចំណែកស្គរដៃ ដែលគេទះយូរៗម្តងជាចង្វាក់ក្នុងពេលប្រគំ គឺតំណាងឱ្យកន្ទុយសត្វខ្លាដែលទះគឹបៗទៅនឹងដីនោះឯង។* ចួនកាលនៅក្នុងពិធីឡើងអ្នកតានេះ ក៏មានថែមឧបករណ៍ប៉ីអរមួយទៀតដែរ។ រឿងនិទាននេះ បានដំណាលតៗគ្នាជាច្រើនជំនាន់រហូតមកទល់សព្វថ្ងៃ ដែលពួកគាត់ជឿជាក់ថា ឧបករណ៍ភ្លេងភ្លយ គឺកើតឡើងដោយសារការត្រាប់តាមសំឡេងសត្វកន្លង់រោមផ្កា។

Grandpa Yim Yun narrated the story of the instrument:

*Once upon a time, there was a king (he could not recall the name) who ordered a hunter to hunt animals in the deep forest. When he reached the heart of the forest, the hunter was stunned by an amazing scene. There was a pair of bantengs fighting each other fiercely and a swarm of bumblebees noisily buzzing around flowers, above those two bantengs. At that moment, a tiger was hiding in the nearby bushes ready to attack the bantengs, but unconsciously it tapped its tail in rhythm while the hunter was dazed and distracted from shooting at the bantengs. This all happened because the beautiful scenery was too spectacular in the thick forest.*

*The hunter returned to tell the king about the story and the king ordered the hunter to imitate the scene, mimicking exactly what he had seen. The hunter arranged an ensemble to imitate the scenery with the Phloy representing the swarm of bumblebees buzzing sound, two men wearing banteng headdresses dancing to the melody accordingly and the hand drum tapping occasionally to mimic the tail of the tiger slapping the ground.*

Sometimes, a mouth organ instrument called the Pei-Or was added to the ensemble at the Neak Ta spirit ritual. This tale has been told throughout many generations until today, which made people believe that the Phloy was born from the buzzing sound of bumblebees' swarm.

# ៣. របៀបធ្វើឧបករណ៍ភ្លយ

# 3. How to Make the Phloy

ដើម្បីផលិតបានជាឧបករណ៍ភ្លយ១ គេត្រូវការឫស្សីពកចំនួន៥ដើម ឃ្លោកទុំ១ ជ័រគគីរ ជ័រម្រោម[១៤] និងវល្លិ៍ផ្ដៅ។ ផ្នែកសំខាន់ៗរបស់ឧបករណ៍ភ្លយគឺ បំពង់សំឡេង ប្រអប់សំឡេង និងអណ្ដាត។ ជ័រម្រោមមាននៅនឹងដើមឈើធំៗមួយចំនួននៅក្នុងព្រៃជ្រៅ ជាហេតុធ្វើឱ្យមានការលំបាកក្នុងការយក។ ចួនកាលគេក៏អាចយកជ័រម្រោមដែលមានរន្ធពីដីមកដែរ ប៉ុន្តែវាមានសភាពស្រួយជាងជ័រនៅនឹងរន្ធដើមឈើ ធ្វើឱ្យបិតមិនជាប់។ ពេលយកជ័រពីរន្ធឈើរួចហើយ គេត្រូវលាងទឹកដើម្បីជម្រុះកំទេចផ្សេងៗ។

In order to make the Phloy, five bamboo pipes, one dried gourd, resin from the Koki tree (Hopea ferrea), resin from the stingless bees (Meliponini) and rattan vines are all required. The core parts of the instrument are the sound tubes, resonator box, and its reeds. It is extremely difficult extracting resin, as it is found only in some large trees deep in the forest. In some cases, resin could be extracted from the holes by the ground, but its quality is crispier than the resin in the holes of the trees, making it not as adhesive. Once the resin has been removed from the holes in the tree's trunk, it is rinsed with water to remove any debris.

*[១៤]ជ័រម្រោមបានមកពីភមរជាតិ១ពួក ស្រដៀងនឹងសត្វឃ្មុំតែតូចៗ ហើយមិនចេះទិចទេ។ វាតែងធ្វើសំបុកនៅក្នុងរន្ធឈើមានទឹកផ្អែមឈ្មុយនិងមានជ័រខ្មៅហៅថាជ័រម្រោមនេះឯង (វចនានុក្រមខ្មែរ ១៩៦៨ ទំព័រ៩២៤)*



រូបទី៥៖
**ដើមឫស្សី**

Photo 5:
**Bamboo for making the Phloy**



រូបទី៦៖
**ឃ្លោកទុំ**

Photo 6:
**Drying birdhouse gourd**

ដំបូងគេយកឫស្សីពកតូចល្មមចំនួន៥ដើម មកកោសសម្អាតឱ្យស្អាតទើបដាក់ហាលឱ្យស្ងួត រយៈពេល៣ទៅ៤ថ្ងៃ។ ប្រវែងឫស្សីទាំង៥ មិនស្មើគ្នាទេ មានវែង មានខ្លីទៅតាមលំដាប់លំដោយ។ ឫស្សីវែងជាងគេ មានប្រវែង១.១៣ម៉ែត្រ, ឫស្សីវែងបន្ទាប់មានប្រវែង ៨០សង់ទីម៉ែត្រ, ឫស្សីបន្ទាប់ទៀតមានប្រវែង ៧១សង់ទីម៉ែត្រ, ឫស្សីបន្ទាប់ទៀតមានប្រវែង ៦៣សង់ទីម៉ែត្រ, រីឯឫស្សីខ្លីជាងគេមានប្រវែង ៥៥សង់ទីម៉ែត្រ។ ឫស្សីទាំង៥ដើម មានឈ្មោះសម្គាល់ខុសៗគ្នាដូចជា ដើមវែងជាងគេហៅថាមេ ឫស្សីវែងបន្ទាប់ហៅថាកូនទី១ ឫស្សីទី៣ហៅថាកូនទី២ ឫស្សីទី៤ជាកូនទី៣ ឫស្សីខ្លីជាងគេ ហៅថាកូនទី៥។

គេតំរៀបឫស្សីទាំង៥ដើមចងផ្ដោបគ្នា ដោយប្រើខ្សែក្រណាត់ធម្មតាសិន។ បន្ទាប់មកគេយកឫស្សីមកបិតឱ្យស្ដើងមានប្រវែងប្រហែល៤សង់ទីម៉ែត្រ រួចចោះបង្ហើបដើម្បីឱ្យឮសំឡេង។ គេត្រូវធ្វើអណ្ដាត៥ សម្រាប់បំពង់ឫស្សី៥។ ដើម្បីឱ្យអណ្ដាតទាំង៥មានសំឡេងខុសគ្នា គេបន្ដក់ជ័រម្រោមនៅលើអណ្ដាតដែលធ្វើរួចត្រង់ផ្នែកខាងចុង។ បើចង់បានសំឡេងធំគ្រលរឬទាប ត្រូវបន្ដក់ជ័រឱ្យច្រើន តែបើសិនជាចង់បានសំឡេងតូចឬខ្ពស់ជាងនេះបន្តិច ត្រូវបន្ថយជ័រឱ្យតិចល្មម។ ក្រោយសាកសំឡេងឃើញថាមានសំឡេងល្អប្លែកៗគ្នាហើយ គេយកបំពង់ឫស្សីទាំង៥មកចោះ ឱ្យសមល្មមនឹងដាក់អណ្ដាតចូល រួបទើបយកជ័រម្រោមដែលស្ងោរលាយជាមួយជ័រគគីរមកបិតឱ្យជាប់។ បន្ទាប់មកគេត្រូវចោះឃ្លោកទម្លុះពីម្ខាងទៅម្ខាងទៀត យកគ្រាប់ចេញឱ្យអស់។ ក្រោយពីស៊កឫស្សីចូលតាមចន្លោះឃ្លោករួចហើយ គេចាប់ផ្ដើមស្ងោរជ័រគគីរនិងជ័រម្រោមលាយគ្នា រួចទើបយកជ័រក្ដៅនោះមកលាបភ្ជិតដើមឫស្សី នឹងឃ្លោកកុំឱ្យចេញខ្យល់។ គេត្រូវលាយជ័រគគីរឱ្យតិចជាងជ័រម្រោមដើម្បីឱ្យល្បាយនោះជាប់បានយូរ។ សព្វថ្ងៃនេះពិបាកក្នុងការរកជ័រម្រោមណាស់ យ៉ាងហោចណាស់គេត្រូវប្រើពេល២ខែដើម្បីបានជ័រម្រោមមកបិតភ្លយមួយដោយសារការកាប់រានដីដើម្បីដាំដំណាំផ្សេងៗរបស់អ្នកស្រុក ទើបធ្វើឱ្យការរកជ័ររឹតតែមានការលំបាក។

The process begins by scraping clean the five bamboo pipes and then drying them for three to four days. The lengths of the five bamboo pipes are not equal, they are long to short in sequence. The longest bamboo pipe is 113 cm long, the next is 80 cm, the next one is 71 cm, the following one is 63 cm, and the shortest bamboo is 55 cm long. The five bamboo pipes have different names, such as the longest pipe, which is called "Mother", the next longest is called "First Child", the next one is called "Second Child", the following one is called "Third Child", and the shortest bamboo is called "Fourth Child".

The five bamboo pipes are tied together using a simple fabric string. Then, the bamboo tubes are thinned to a length of approximately 4 cm and pierced to make a sound. Then they need to make five reeds on the five bamboo pipes. To make the five reeds produce sound differently, a drop of resin is applied to the tip of the reed. Adding more drops of resin, will produce a high pitch sound and less resin will produce a low pitch sound. After testing the sound to ensure that different tones can be produced, the five bamboo pipes are pierced to install reeds, then resin mixture is boiled to paste the pieces together. Next, take the dried gourd and neatly empty it and pierce it through from side to side. After inserting the bamboo pipes into the gourd, apply the boiling resin mixture to seal the bamboo and gourd to keep the air out. The mixed resin requires less resin from trees and more resin from stingless bees in order to make a good quality solution. Nowadays, it is harder to acquire the resin from the stingless bees, it takes at least two months to get just enough for making one Phloy, because the large land containing the resin has been cleared for farming.

រូបទី៧៖
**លោកតា ឌួង ញឹក កំពុងធ្វើ ឧបករណ៍ភ្លយ**

Photo 7:
**Grandpa Duong Nhek making the instrument**





រូបទី៨៖
**អណ្ដាតភ្លយ**

Photo 8:
**The reeds of the Phloy**

បន្ទាប់មក គេត្រូវយកដែកដុតឱ្យក្ដៅ មកចោះបំពង់ឫស្សីឱ្យមានទំហំប៉ុនៗគ្នា ធ្វើជារន្ធបិទបើកសំឡេង។ គេចោះបំពង់ឫស្សីតែ៤ទេ បំពង់ឫស្សីដែលវែងជាងគេ មិនចោះឡើយ។ គេក៏ត្រូវចោះរន្ធមួយចំពីលើផ្លែឃ្លោកសម្រាប់ផ្លុំ។ សំឡេងភ្លយពីមួយទៅមួយមិនស្មើគ្នាទេ។ សូម្បីតែការចោះរន្ធសំឡេង ក៏មិនស្មើគ្នាដែរ។ លោកតាឌួង ញ៉ឹកបានឱ្យដឹងថា ***«ភ្លយនីមួយៗត្រូវមានសំឡេងខុសគ្នា តូចផងធំផង មិនរួមគ្នា ចម្រុះគ្នាទើបស្ដាប់ទៅពីរោះហាក់ដូចជាឆ្លើយឆ្លងគ្នា»***[១៩]។ ក្រោយពីបិតផ្លែឃ្លោកភ្ជាប់នឹងបំពង់ឫស្សីរួចហើយ គេក៏ស្រាយក្រណាត់ដែលចងផ្ដោបឫស្សីចេញ ជំនួសវិញដោយខ្សែផ្ដៅ ចងរុំព័ទ្ធឱ្យជាប់ណែន។ ដើម្បីការពារឧបករណ៍ភ្លយពីសត្វល្អិតផ្សេងៗចូលទៅសម្ងំក្នុងបំពង់ឫស្សីនិងស៊ីបំផ្លាញ គេត្រូវធ្វើឆ្នុកសម្រាប់ចុករន្ធទាំងអស់នៅលើឧបករណ៍។ បើសិនជាមានសត្វល្អិតចូលទៅក្នុងបំពង់ឫស្សីនោះធ្វើឱ្យភ្លយបាត់បង់សំឡេង។ ឆ្នុកគេធ្វើពីដើមប្រកាំ ដែលអាចរកបាននៅក្បែរៗផ្ទះអ្នកស្រុក។ គេចិតដើមប្រកាំជារាងមូលខ្លីៗល្មមត្រូវនឹងរន្ធបំពង់ឫស្សីនីមួយៗ។

*[១៩]មូលហេតុនេះហើយ ទើបពេលដែលឧបករណ៍ភ្លយច្រើនប្រគំចូលគ្នា ឬប្រគំជាមួយអ្នកច្រៀង ស្ដាប់ទៅសំឡេងមិនត្រូវគ្នាទេ។*

After using a hot iron rod to pierce the bamboo pipes in the same size to make sound holes, the gourd also has a hole drilled on top to create the blowing hole. However, by only making holes on those four bamboo pipes, the longest one will not be drilled. The Phloy sound intervals are not equal and even the sound holes are not equal. Grandpa Duong Nhek stressed that ***"each Phloy must have a different sound; high pitch, low pitch, and an incongruous mixture of sounds. It sounds beautiful when each instrument speaks to each other."***[11]. After cementing the gourd to the bamboo pipes, the cloth string is untied, instead a rattan rope is used to wrap tightly around the bamboo pipes. To protect the instrument from insects entering the bamboo tubes and getting ruined, all the holes will be plugged firmly. If there are insects in the bamboo pipes, the instrument will lose its sound. The plugs were made of a type of plant called Prokam, which can be found around the houses of the locals. The plant was cut into a short roll, enough to fit each hole.

[11] *That is why when more Phloys perform together or with a singer, they won't produce a harmonious sound.*



រូបទី៩៖
**ដើមប្រកាំ**

Photo 9:
**Prokam plant**



រូបទី១០៖
**ជ័រគ្រោម**

Photo 10:
**Resin from stingless bees**

# ៤. បទភ្លេងនិងចម្រៀង
# 4. Melodies & Lyrics

ខាងក្រោមនេះ ជាពាក្យច្រៀងដែលខ្ញុំបានពីសិស្សរបស់លោកតា ឌួង ញឹក ឈ្មោះ ព្រំ ចិន និងលោក ឡូ ទិត។ ពាក្យច្រៀងខ្លះ ជាភាសាប្រចាំតំបន់អារ៉ែង ព្រោះរកអត្ថន័យនៅក្នុងវចនានុក្រមពុំមានឡើយ។ ដូច្នេះខ្ញុំបានសរសេរទៅតាមសំនៀងអ្នកច្រៀង បើសិនជាសួររកអត្ថន័យពិតជាពិបាក ដោយសារអ្នកច្រៀងគាត់ក៏ពុំយល់ន័យនេះដែរ គឺគ្រាន់តែចេះតាមគ្រូប្រាប់។

Below are the lyrics, I got from Mr Lo Tith and Grandpa Duong Nhek's student, Mr Prom Chen. Some wordings are in the dialect of the Areng region; they can't be found in the Khmer dictionary. Thus, I transcribed according to the local singers and asked for the meaning; this is really problematic because the singers do not understand the meaning either, they just memorised by heart from their teachers, passing the words on from generation to generation.

## និមន្តគ្រូតូច **Inviting Little Teacher** *(Nimun Kru Touch)*

១. ហាអេអើយលោកនិមន្តអើយពីលើមកណា លោកអើយ ពីលើលោកណា លោកកាន់ទាំងផ្លិតទាំងក្រដាស អេអើយលោកនិមន្តអើយពីលើអាំងណា លោកកាន់ទាំងមាសកំប្លង់មែនដឹង

២. អេអើយអញ្ជើញលោកគ្រូតូចណាលោក អើយកំពូលអើយប្រាភ្នំ អេអើយអញ្ជើញលោកគ្រូធំណា លោកអើយ ពីភ្នំបាតឌៃ បាតឌៃ ពីភ្នំបាតឌៃ។

1. Haahoey,… Oh the Lord is descending from the above, from the above, Haahoey,… You are holding a fan and paper, Haahoey,… You are coming from the above, you are holding gold, is it true?

2. Haahoey,… Inviting little teacher from Pra Mount, Haahoey,… Inviting grand teacher, a grand teacher from Batde Mount, Batde Mount.

## បទសម្រាប់ពិធីក្រុងពាលី

## **Song for Ritual Krong Peali** *(Pitie Krong Peali)*

១. ស្វាយអាត់ អេអើយ អេអើយ កំសត់អើយ ថ្លៃអើយ បងស្រណោះអើយស្រី ស្វាយអាត់ អេ

២. ដើរជីកស្តើងកាត់ ដើរជីកស្តើងកាត់អើយ ស្តើងអើងអើយ រាត់រាយតាមស្រែ ឱត្រពាំងលលៃ

៣. ព្រឹកអើយមាន់ព្រឹក អើយៗ អេអើងអើយ កំសត់ស្រីអើយ ស្រីអើយមាន់ព្រឹក អើយជន្សើម (សន្សើម) នាងរាស់ស្លឹក អើយស្តើង អើយស្តើង មាន់ព្រៃ តូចស្រីអញរងារល្វៃ។

៤. យកជុងទៅចាក់អេអើយ អើងអើយ អើយកំសត់ អើយថ្លៃអើយ យកជុងធ្លាក់តូចស្រីទៅរាយ អើយ

៥. ឮមាន់ព្រៃណា ណេមាន់ព្រៃតូចស្រីរងារ អេអើយមាន់ព្រៃនាងរងារ ស្តើងបងអើយ ឱរំពងចូលព្រៃ ឱព្រៃឆា អេឱរណាណាថ្លៃអើយ ឱរំពងចូលព្រៃ ឱព្រៃឆា។

*ច្រៀងដោយលោក ឡូ ទិត នៅភូមិចំណារ ស្រុកថ្មបាំង។ មុននឹងរៀបចំពិធីអ្វីមួយ គេត្រូវច្រៀងបទក្រុងពាលីនេះជាមុនសិន។*

1. Svay Ath, Heehoey,… so sad dear, I'm so pitiful to my dear Svay Arth, Heehoey,…

2. Walking, walking, Heehoey,… along the rice field, oh lake …

3. Ooh it's dawning time, Heeheoy,… so sadness dear, dew dropping on tree leaves, the roosters' crow sounds from very far away.

4. Putting up a trapped, Heehoey,… Oh dear, using bait, Heehoey,…

5. Hearing the roosters crowing, oh dear, roosters crowing, resounding in the forest, oh dear, roaring in the forest.

*Sung by Mr Lo Tith at Chamna village, Thmor Bang district. Before beginning any rite, this song must be heard first.*

## បទពីនាយធ្លាក់អាយ

## Coming from Far to Here *(Pii Neay Thleak Ai)*

១. ហា អេអើយ ខ្ញុំមកពីនាយអើយខ្ញុំធ្លាក់អាយ ខ្ញុំធ្លាក់អាយណា ម្ចាស់ថ្លៃអើយ ហាអេអើយ ឱ្យខ្ញុំទីពឹងលោកណា ឱ្យទីពឹង លោកយាយ លោកតា ក្រែងគ្រងរក្សាណាខ្ញុំផង ខ្ញុំផង

២. ហាអេអើយក្រែងតែជើងអើយខ្ញុំភ្លាត់ណា ខ្ញុំភ្លាត់ណា លោកយាយស្រី ក្រែងមាត់តែខ្ញុំខុសឆ្គងដឹង លោកដឹង អេអេអើយ ក្រែង គ្រងរក្សាណាខ្ញុំផង ខ្លួនខ្ញុំនៅក្មេងដឹង លោកដឹង អេអើយ។

1. Haahoey,… I came from so far away, I arrived here, I am here, Ooh Lord, Haahoey,… Who may I depend on, I depend on grandma, grandpa taking care of me, please!

2. Haahoey,… If my feet slip, I slip, Ooh lord grandma, if my mouth utters wrong words, you know, Haahoey,… Please take good care of me, I am still young, you know! Haahoey,…

*ច្រៀងដោយលោក ព្រំ ចិន សិស្សរបស់លោកតា ឌួង ញ៉ឹក។ Sung by Mr Prom Chen, a student of Grandpa Duong Nhek.*

## បទពីនាយធ្លាក់អាយ Coming from Far to Here *(Pii Neay Thleak Ai)*



## ស្ទឹងបែកជាពីរ

## **River Splits into Two** *(Stoeung Bek Chea Pii)*

១.  ហាអេអើយ ពេលព្រឹកព្រលឹម ឮសូរមាន់រងាវ ពេលថ្ងៃរសៀល ស្តាប់សំឡេងទោចយំ  កង្កែបភ្នាត់យំ នៅក្បែរអើយឱមាត់ទឹក ខ្យល់បក់រសេច ស្ទឹងបែកជាពីរ ស្ទឹងមួយឈ្មោះស្ទឹងតូច មួយឈ្មោះស្ទឹងធំ  ត្រីត្របាក់ព្រុងៗ នៅក្បែរអើយ អើយមាត់ពាម មាត់ពាម អេអើយ។

1.  Haahoey,… In the early morning, hearing the roosters crowing, in the afternoon, listening to the gibbons and frogs crying and singing near the water, breezy air, the river splits into two, namely the small river and the big river, so many fishes swim around, Haahoey,…

## ស្ទឹងបែកជាពីរ River Splits into Two *(Stoeung Bek Chea Pii)*



## វាលស្រែវាលស្រុក

## **Rice field, Hometown** *(Veal Sre Veal Srok)*

១.  ហាអេអើយ វាលស្រែអើយឱវាលស្រុក វាលស្រែស្រដុក វាលស្រុកបុរាណ ធ្វើស្រែអើយឱត្រដុក លលកមិនដែលដាក់ស៊ី (ពីរដង)

1.  Haaheoy,... Oh the rice field, oh my hometown, earliest farming village, oh we never caught the dove for eating. (two times)

## វាលស្រែវាលស្រុក Rice field, Hometown *(Veal Sre Veal Srok)*



## សែនអ្នកតាស្រុក **Homage Neak Ta Spirit** *(Sen Neak Ta Srok)*



## ថ្ងៃរៀបលិច Dusking Sunset *(Thagnai Reap Lech)*



# ៥. សន្និដ្ឋាន Conclusion 5.

សិល្បៈនិងវប្បធម៌ជាអត្តសញ្ញាណដោយឡែករបស់ប្រទេសមួយ ឬជនជាតិមួយ ដែលបម្រើឱ្យការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនគ្រប់រូប។ ហេតុដូចនេះហើយការថែរក្សាអត្តសញ្ញាណ ជារឿងដែលគួរធ្វើជាបន្ទាន់ដើម្បីបន្តមរតកទាំងនេះដល់មនុស្សជំនាន់ក្រោយ។ ដូចជាឧបករណ៍ភ្លេងភ្លយ ជាឧបករណ៍ភ្លេងកម្រមួយដែលស្ទើរតែគ្មាននរណាស្គាល់នៅក្នុងតំបន់អារ៉ែង។ បើសិនគ្មានការផ្ទេរចំណេះដឹងបន្តទៀតទេ ឧបករណ៍ភ្លេងភ្លយអាចនឹងបាត់បង់ទៅតាមពេលវេលា។ ការកត់ត្រាអក្សរភ្លេងនិងចងក្រងពីប្រវត្តិខ្លះៗ ព្រមទាំងវិធីធ្វើឧបករណ៍ភ្លយ គ្រាន់តែជាផ្នែកមួយ ក្នុងការរួមចំណែករក្សាឯកសារនិងផ្សព្វផ្សាយបន្ត ឱ្យប្រជាជនទូទៅបានស្គាល់តែប៉ុណ្ណោះ។ ម៉្យាងទៀត អក្សរភ្លេងដែលកត់ត្រាតាមបញ្ញារខាបស្ចិមប្រទេសមកនេះ ក៏មិនបានសុក្រឹត១០០ភាគរយតាមអ្វីដែលបានឮឡើយ។ ដោយហេតុថាកំរងសំនៀងខ្មែរនិងកំរងសំនៀងបស្ចិមប្រទេសមិនដូចគ្នាឡើយ។ ម៉្យាងទៀតការដែលរៀនតាមតែណោតភ្លេង គឺអាចនឹងបាត់បង់ពណ៌សម្បុរនិងចរិតរបស់បទភ្លេង។ អ្វីដែលសំខាន់ គឺត្រូវបង្កលក្ខណៈឱ្យឧបករណ៍ភ្លយមានឱកាសសម្តែងជាសាធារណៈ ជាពិសេសនោះម្ចាស់ស្រុកផ្ទាល់ត្រូវយល់ដឹងពីសារសំខាន់ក្នុងការអភិរក្សមរតកសិល្បៈអរូបី។

Arts and culture are the distinctive identity of a country or an ethnic group that serves the daily lives of every person. Therefore, safeguarding an identity is an urgent task in order to pass on the heritage to the next generation. For instance, this musical instrument is almost unknown in the Areng region. Without continuing knowledge transference, the Phloy will be lost over time. Recording musical notation and documenting history, including the instrument-making process, is simply a small element in safeguarding documentation and dissemination for the sake of general public awareness.

On the other hand, using the Western musical notation to document is not 100% accurate just by hearing. The reason is that the scales and pitch frequencies of traditional Khmer and Western music are characteristically different. Besides, learning music solely from the music notes may lose the colours and characteristics of the music. The most important fact is to create ample opportunities to perform for public audiences, most notably the local owners themselves must understand the significance of safeguarding intangible cultural heritages.

# ឯកសារពិគ្រោះ References

១. កែវ ណារុំ (២០០៥) «មរតកតន្ត្រីខ្មែរ» បោះពុម្ពផ្សាយលើកទី១ នៅភ្នំពេញ

២. ម៉ៅ សោភ័ណ និង រស់ សំណាង (២០០១) «ប្រវត្តិឧបករណ៍ភ្លេងពួយ» កម្ពុជសុរិយា៖ ទស្សនាវដ្តីផ្សាយអក្សរសាស្ត្រសាសនា និងអក្សរសាស្ត្រទូទៅ, បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, លេខ៤ ទំព័រ៨៨-៩៣

៣. គណៈកម្មការស្រាវជ្រាវវប្បធម៌អរូបីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងអង្គការយូណេស្កូ (២០០៤) »បញ្ជីសារពើភ័ណ្ឌបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា», សហការបោះពុម្ពផ្សាយដោយក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងយូណេស្កូ, បោះពុម្ពនៅប្រទេសកម្ពុជា

៤. គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ (២០០៣) «ទស្សនីយភាពខ្មែរ»

៥. យន់ ខៀន, កែវ ដូរីវ៉ាន់, អ៊ី លីណា និង ម៉ៅ ឡេណា (២០០៣) «ឧបករណ៍តន្ត្រីបុរាណកម្ពុជា» បោះពុម្ពលើកទី២ នៅភ្នំពេញ

1. Keo Narom. (2005). Cambodian Music. Phnom Penh: First Edition.

2. Mao Sophorn, and Ros Samnang. (2001). "History of the Phloy musical instrument". Kambuja Suriya Journal Issue 4, (2001): 88-93. Phnom Penh: Buddhist Institute.

3. Intangible Cultural Heritage Committee, MoCFA. (2004). Inventory of Intangible Cultural Heritage of Cambodia. Phnom Penh: UNESCO & MoCFA.

4. Research Committee for Arts and Culture. (2003). Khmer Performing Arts. Phnom Penh

5. Yun Khean, Keo Dorivan, Y Lina, and Mao Lenna. (2003). Traditional Musical Instruments of Cambodia. Phnom Penh: UNESCO, Second Edition.

# អ្នកផ្តល់ព័ត៌មាន Key Informants

១. លោកតា ឌួង ញ៉ឹក អ្នកផ្លុំភ្លួយរស់នៅភូមិព្រៃកស្វាយ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង
២. លោក ទិត្យ លី ប្រធានសហគមន៍អេកូទេសចរណ៍តំបន់អារ៉ែង
៣. លោកតា ឃឹម យន់ អ្នកច្រៀងនិងលេងស្គរ នៅភូមិកោះ ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង
៤.លោក ឡូ ទិត អ្នកច្រៀងនិងលេងស្គរនៅភូមិភូមិចំណារ ឃុំប្រឡាយ ស្រុកថ្មបាំង ខេត្តកោះកុង
៥. លោក ព្រំ ចិន សិស្សរបស់លោកតាឌួង ញ៉ឹក
៦. លោក សៀង ថន មេឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង
៧. លោក ស៊ុន មានជ័យ ប្រធានមន្ទីរវប្បធម៌ខេត្តកំពង់ស្ពឺ
៨. អ្នកស្រី ផែន សុផាន់ណា ប្រធានការិយាល័យអភិវឌ្ឍន៍វប្បធម៌នៃមន្ទីរវប្បធម៌ខេត្តពោធិ៍សាត់

1. Grandpa Duong Nhek, Phloy music player at Pray Svay village, Thmor Daun Pov commune, Thmor Bang district, Koh Kong province.
2. Mr Tith Ly, Chief of the Steung Areng Community-Based Ecotourism.
3. Grandpa Yim Yun, Vocalist and Drum Player at Koh village, Thmor Daun Pov commune, Thmor Bang district, Koh Kong province.
4. Mr Lo Tith, Vocalist and Drum Player at Chamnar village, Prolay commune, Thmor Bang district, Koh Kong province.
5. Mr Prom Chen, Student of Grandpa Duong Nhek.
6. Mr Sieng Thorn, Chief of Commune Thmor Daun Pov, Thmor Bang district, Koh Kong province.
7. Mr Sun Meanchey, Director of Kampong Speu Service of Culture and Fine Arts.
8. Mrs Phen Sophanna, Chief Office for Culture Development of the Service of Culture and Fine Arts, Pursat province.

# ស្ថាប័នសហការ Institutional Partners

រថយន្តតន្ត្រីទិព្វខ្មែរនៃអង្គការសិល្បៈខ្មែរអមតៈ សូមថ្លែងអំណរគុណដល់ មូលនិធិឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកសម្រាប់ការអភិរក្សវប្បធម៌ សម្រាប់មូលនិធិឧបត្ថម្ភផ្តួចផ្តើមបើកថ្នាក់ភ្លយ, សមាគមសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង សម្រាប់កិច្ចសហការសម្របសម្រួលជាមួយថ្នាក់ភ្លយ និងអ្នកផ្តល់ជំនួយនិងអ្នកគាំទ្រសិល្បៈខ្មែរអមតៈ សម្រាប់ជំនួយឧបត្ថម្ភធ្វើឲ្យការស្រាវជ្រាវនិងការចងក្រងឯកសារនេះដំណើរការទៅបាន។ យើងក៏សូមថ្លែងអំណរគុណដល់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលតែងតែផ្តល់ការគាំទ្ររាល់កម្មវិធីនិងគម្រោងសិល្បៈវប្បធម៌របស់យើង។

ស្រាវជ្រាវនិងសរសេររបាយការណ៍លទ្ធផលដោយ វ៉ា បុប្ផារី
ត្រួតពិនិត្យអត្ថបទភាសាខ្មែរដោយ ឥន្ទ សម៉ាណាក់
បកប្រែអត្ថបទពីភាសាខ្មែរទៅភាសាអង់គ្លេសដោយ សួន ប៊ុនរិទ្ធ
ត្រួតពិនិត្យអត្ថបទភាសាអង់គ្លេសដោយ Kiana Duncan
រចនាសៀវភៅដោយ តាន់ វត្តី

The Khmer Magic Music Bus of Cambodian Living Arts (CLA) acknowledges the U.S. Ambassadors Fund for Cultural Preservation (AFCP) for their financial support of the launch of the Phloy class; the Steung Areng Community-Based Ecotourism Association for their collaboration in facilitating the Phloy class; and individual CLA donors and supporters for their generous contributions toward making this Phloy research and documentation possible. We also acknowledge the Ministry of Culture and Fine Arts for their continued support of all of our cultural programs and projects.

Researched and written report by Va Bophary
Proofread Khmer text by En Sormanak
Translated from Khmer to English language by Suon Bunrith
Proofread English text by Kiana Duncan
Designed book by Tan Vatey

